ធនាគារជាតិ នៃ កម្ពុជា

លេខ.......................................................

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ឈ្មោះ ៖ ជា ដារ៉ា
លេខទូរស័ព្ទ ៖ ០២៣ ៧២២៥៦៣ (១១៣៤)
អ៊ីមែល ៖ psd@nbc.org.kh

# ការចុះហត្ថលេខាលើកំណត់ត្រានៃកិច្ចពិភាក្សា
# ស្តីពី
# គម្រោងអភិវឌ្ឍប្រព័ន្ធទូទាត់រាយសម្រាប់ប្រទេសកម្ពុជា

ប្រព័ន្ធទូទាត់គឺជាហេដ្ឋារចនាសម្ព័ន្ធហិរញ្ញវត្ថុដ៏សំខាន់មួយរបស់ប្រទេសដែលមានតួនាទីរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការផ្តល់នូវមធ្យោបាយសម្រាប់សម្រួលដល់ការទូទាត់ក្នុងសកម្មភាពពាណិជ្ជកម្មប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងឆាប់រហ័ស ។ បច្ចុប្បន្ន ធនាគារជាតិនៃកម្ពុជាបាននិងកំពុងផ្តោតជាសំខាន់លើការអភិវឌ្ឍប្រព័ន្ធទូទាត់រាយជាការងារអាទិភាព ក្នុងគោលដៅកាត់បន្ថយការប្រើប្រាស់សាច់ប្រាក់និងជំរុញការទូទាត់ជាអេឡិចត្រូនិកក្នុងសេដ្ឋកិច្ច ព្រមទាំងលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍវិស័យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ។

អាស្រ័យដោយមើលឃើញពីសារៈសំខាន់នេះ នៅថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៦ ធនាគារជាតិនៃកម្ពុជាបានចុះហត្ថលេខាលើកំណត់ត្រានៃកិច្ចពិភាក្សាស្តីពី គម្រោងអភិវឌ្ឍប្រព័ន្ធទូទាត់រាយសម្រាប់ប្រទេសកម្ពុជា ក្រោមជំនួយរបស់រដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េ តាមរយៈ KOICA ដែលមានទឹកប្រាក់ ៨លានដុល្លារអាមេរិក ។

ជំនួយនេះត្រូវបានរដ្ឋាភិបាលប្រទេសកូរ៉េអនុម័តផ្តល់ឱ្យប្រទេសកម្ពុជា ក្រោមក្របខ័ណ្ឌនៃការចុះអនុស្សរណៈយោគយល់រវាងធនាគារជាតិនៃកម្ពុជា និងធនាគារកណ្តាលកូរ៉េ ស្តីពីការរៀបចំប្រព័ន្ធទូទាត់សងប្រាក់តម្លៃរាយក្នុងប្រទេសកម្ពុជាកាលពីខែធ្នូ ឆ្នាំ២០១៤ ។

ជំនួយរបស់រដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េនេះនឹងត្រូវបានប្រើប្រាស់សម្រាប់អភិវឌ្ឍប្រព័ន្ធ ការរៀបចំវិធាននិងបទប្បញ្ញត្តិពាក់ព័ន្ធ និងការអភិវឌ្ឍធនធានមនុស្ស ក្នុងគោលដៅធ្វើឱ្យប្រព័ន្ធទូទាត់រាយនៅក្នុងប្រទេសកម្ពុជាកាន់តែទំនើប មានសុវត្ថិភាព និងប្រសិទ្ធភាព ឆ្លើយតបទៅនឹងតម្រូវការទីផ្សារ ព្រមទាំងរួមចំណែកដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។

ការអនុវត្តគម្រោងអភិវឌ្ឍក្រោមជំនួយរដ្ឋាភិបាលសាធារណៈរដ្ឋកូរ៉េនឹងរួមចំណែកពង្រឹងចំណង មិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋកូរ៉េ ជាពិសេស ទំនាក់ទំនងរវាងធនាគារកណ្តាលប្រទេសទាំងពីរ ឱ្យកាន់តែល្អប្រសើរឡើង ។

## អំពីធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជាគឺជាធនាគារកណ្តាលរបស់ព្រះរាជាណាចក្រកម្ពុជា ។ ក្នុងនាមជាអាជ្ញាធររូបិយ-វត្ថុនិងត្រួតពិនិត្យប្រព័ន្ធធនាគារនៅកម្ពុជា បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជាគឺកំណត់និង ដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សានូវស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍ សេដ្ឋកិច្ច ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល ៖ www.nbc.org.kh

## សូមភ្ជាប់ទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា

www.facebook.com/nationalbankofcambodiaofficial
www.twitter.com/nbccambodia
www.youtube.com/nationalbankofcambodia